# សារាចរលេខ ០១២

# ស្តីពីការអនុវត្តន៍វិធាន
# ការអនាម័យ និងសន្តិ
# សុខការងារ នៅតាម
# គ្រឹះស្ថានផលិតកម្ម

ដែលដឹកនាំនិងឧបត្ថម្ភដោយ

-ឯកឧត្តម ជីវ សុខហាក់

-ឯកឧត្តម ប៊ុន ហុន ចំនួន៨00$

-ឯកឧត្តម កើត រិទ្ធ

-លោក តាន់ សេណារ៉ុខ

ឯកសារនេះត្រូវបានការពារ
ដោយច្បាប់នៃព្រះរាជាណា-
ចក្រកម្ពុជាតាមមាត្រា៣និង
មាត្រា១១ នៃច្បាប់ស្តីពីម៉ាក
ពាណិជ្ជនាម និងអំពើនៃការ
ប្រកួតប្រជែងមិនស្មោះត្រង់
ចុះថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០០២

www.ekasar.com

00216

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសង្គមកិច្ច ការងារ
បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា
លេខៈ ០១២ សកបយ

ភ្នំពេញ, ថ្ងៃទី ០២ ខែ មិថុនា ឆ្នាំ ២០០០

សារាចរ
ស្តីពី
ការអនុវត្តន៍វិធានការអនាម័យ និងសន្តិសុខការងារ
នៅតាមគ្រឹះស្ថានផលិតកម្ម

ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទាសង្កេតឃើញថា នៅតាមគ្រឹះស្ថានផលិតកម្មនានា ការអនុវត្តន៍វិធានការអនាម័យនិងសន្តិសុខការងារ នៅមានការខ្វះខាតគួរអោយព្រួយបារម្ភ ។ ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា សូមផ្តល់នូវការណែនាំជាជំហានដំបូងសំដៅធ្វើអោយ ការអនុវត្តន៍វិធានការ អនាម័យ និងសន្តិសុខការងារទាំងនោះ អោយបានប្រសើរឡើងដើម្បីធានាផលប្រយោជន៍ស្របច្បាប់ដល់គ្រប់ភាគី ដូចតទៅ :-

១-ត្រូវរៀបចំកន្លែងពុះអុសអោយនៅឆ្ងាយពីច្រកចេញចូលនិងឆ្ងាយពីកន្លែងធ្វើការផ្សេងទៀត ហើយត្រូវហាមមិនអោយក្មេងទៅក្បែរកន្លែងនោះទេ ។

២-ចំពោះគ្រឹះស្ថាន ដែលមានប្រើម៉ាស៊ីនអារអុសត្រូវធ្វើគំរបខ្សែពានម៉ាស៊ីនអារអុសអោយបានរឹងមាំហើយត្រូវរៀបចំអោយកម្មករអារអុសឈរសងខាងកន្ទុយអុសពោលគឺហាមឈរទល់មុខផ្លែរណារ ។

៣-ចំពោះគ្រឹះស្ថានផលិតកម្មដែលប្រើអុសនិងអង្កាម ត្រូវសាងសង់រោងម៉ាស៊ីនផលិតកម្មអោយបានរឹងមាំនិងប្រក់ដំបូលអោយបានជិត ។

៤-ចំពោះការប្រើម៉ាស៊ីនកិនដីផលិតកម្មដោយប្រើធ្លើ ត្រូវសាងសង់អោយបានរឹងមាំ ទាំងធ្លើទាំងសសរទ្រធ្លើ ។ ទំងន់ដីដែលដាក់លើធ្លើ ត្រូវអោយសមាមាត្រជាមួយនិងធ្លើ ។ កម្មករដែលធ្វើការនៅទីនោះមិនត្រូវអោយឡើងអង្គុយលើធ្លើដើម្បីកាប់ដីច្បាក់ចូលប្រហោងប្រដាប់កិនដីទេពោលគឺកម្មករត្រូវឈរសងខាងធ្លើ

www.ekasar.com

ដើម្បីកាប់ដីញាត់ចូលប្រហោងកិនដី ដោយមិនត្រូវប្រើដៃឬជើងលូកចូលក្នុងប្រហោងកិនដីទេ ។ ខ្សែពានម៉ាស៊ីនកិនដីត្រូវមានគំរបការពាររឹងមាំ ។

៥-ចំពោះការប្រើប្រាស់ម៉ាស៊ីនកិនដីដោយគ្មានប្រើធ្នើ ត្រូវសាងសង់រោងអោយបានគត់មត់សំរាប់កម្មករបានធ្វើការក្នុងម្លប់ ។ គ្រឿងយន្តកិនដីផលិតឥដ្ឋនៅត្រូវមានគំរបការពារនិងគំរបការពារខ្សែពានអោយបានរឹងមាំ ។កម្មករដែលធ្វើការនៅទីនោះ មិនត្រូវយកដៃលូកចូលក្នុងប្រហោងប្រដាប់កិនដីដើម្បីសង្កត់ដីទេ ត្រូវប្រើឧបករណ៍ផ្សេងសំរាប់ចុកដីបញ្ចូលក្នុងប្រហោងនោះវិញ ។

៦-ត្រូវរៀបចំបណ្តាញអគ្គីសនីអោយបានត្រឹមត្រូវតាមលក្ខណៈបច្ចេកទេសអគ្គីសនី ដោយរៀបចំអោយមានប្រអប់សំរាប់ដាក់កុងតាក់បិទបើកចរន្តអគ្គីសនី និងគំរប ការពារកុងតាក់អោយបានត្រឹមត្រូវ ។

៧-ចំពោះគ្រឹះស្ថានដែលមានប្រើម៉ាស៊ីនភ្លើង ត្រូវផ្លាស់ប្តូរបំពង់ផ្សែងម៉ាស៊ីន ដែលពុកធ្លុះធ្លាយចេញជាប្រចាំ ។ ត្រូវរៀបចំធុងទឹកម៉ាស៊ីនអោយនៅក្រៅជញ្ជាំងរោងម៉ាស៊ីនភ្លើងហើយមិនត្រូវស្តុកទុកប្រេងម៉ាស៊ូត ឬប្រេងម៉ាស៊ីននៅក្នុងរោងម៉ាស៊ីនភ្លើងទេ គោលគឺត្រូវទុកដាក់ប្រេងទាំងនេះនៅទីកន្លែងផ្សេង ។

៨-ចំពោះកម្មករដែលធ្វើការនៅឡដុតឥដ្ឋ ត្រូវមានសំភារៈការពារពេលកម្មដូចជា សំលៀកបំពាក់ក្រាស់ ស្រោមដៃក្រណាត់ក្រាស់ ស្បែកជើងក្រណាត់ ឬស្បែក " កវែង" ម្ហូកនិងវ៉ែនតាខ្មៅជាដើម ។

៩-ចំពោះការប្រើប្រាស់កម្មករ និយោជិត ដែលមានអាយុពី ១៥ ទៅក្រោម ១៨ឆ្នាំ ត្រូវធានាថាការងារនោះ មិនបណ្តាលអោយប៉ះពាល់ដល់ សុខភាព សន្តិសុខ ឬសីលធម៌របស់មនុស្សពេញវ័យ ដោយសារតែលក្ខខណ្ឌ ឬប្រភេទរបស់មុខរបរ និងការងារទាំងនោះបង្កឡើង ។

ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា មានសេចក្តីសង្ឃឹមយ៉ាងមុតមាំថាអស់លោក លោកស្រីជាម្ចាស់ និងនាយកគ្រឹះស្ថានផលិតឥដ្ឋទាំងអស់ច្បាស់ជាយកចិត្តទុកដាក់អនុវត្តតាមការណែនាំខាងលើបានល្អប្រសើរជាពុំខាន ។៚

រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

អ៊ិត សំហេង

<u>ចម្លងជូន</u>

-ខុទ្ទកាល័យព្រះមហាក្សត្រ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ទីស្តីការគណៈរដ្ឋមន្ត្រី
-គ្រប់ក្រសួងពាក់ព័ន្ធ "ដើម្បីជូនជ្រាប"
-អគ្គនាយកដ្ឋាន ការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ "ដើម្បីផ្សព្វផ្សាយ និងអនុវត្ត"
-គ្រប់មន្ទីរសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ខេត្ត- ក្រុង "ដើម្បីផ្សព្វផ្សាយ និងអនុវត្ត"
-សមាគមនិយោជក "ដើម្បីជ្រាប"
-សហភាពសហជីព "ដើម្បីជ្រាប"
-គ្រប់បណ្តាញវិទ្យុ និងទូរទស្សន៍ "ដើម្បីជួយផ្សព្វផ្សាយ"
-រាជកិច្ច
-កាលប្បវត្តិ និង ឯកសារ